ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

ក្នុងនាមប្រជារាស្ត្រខ្មែរ
សាលាឧទ្ធរណ៍ភ្នំពេញ

* * * * * * * * * *

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ១៤៥

ចុះថ្ងៃទី ២៣_០១_២០០៧

សាលដីកា

លេខ : ២៩ "ខ"

ចុះថ្ងៃទី ១១_០៣_២០០៩

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១១-០៣-២០០៩ ដោយមានសមាសភាពដូចខាងក្រោម:

ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

លោក [redacted]

ក្រឡាបញ្ជី

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ១៤៥ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៧ ដែលមាន:

១- ជនជាប់ចោទឈ្មោះ [redacted] សីហា ហៅ ភ័ក្រ្ត ភេទប្រុស អាយុ ១៦ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករលើកឥវ៉ាន់ ទីលំនៅ [redacted] ខណ្ឌមានជ័យ ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី២២-០៣-២០០៦។ (**ប្តឹងឧទ្ធរណ៍**)

មានលោក [redacted] សុភី ជាមេធាវីការពារ។

២- ជនជាប់ចោទឈ្មោះ [redacted] សារ៉ាក់ ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីលំនៅសព្វថ្ងៃផ្ទះគ្មា [redacted] ខណ្ឌមានជ័យ ក្រុងភ្នំពេញ ឪពុកឈ្មោះ អត់ស្គាល់ ម្តាយឈ្មោះ [redacted] "ស" នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ២២-០៣-២០០៦។

៣- ជនជាប់ចោទឈ្មោះ [redacted] ស៊ីថា ហៅ ថា ភេទប្រុស អាយុ ១៨ឆ្នាំ មុខរបរមិនពិតប្រាកដ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៣០C ក្រុម១៣ [redacted] ឪពុកឈ្មោះ [redacted] រ) ម្តាយឈ្មោះ [redacted] នៅលីវ ទោសពីមុនគ្មាន។

៤- ជនជាប់ចោទឈ្មោះ [redacted] សុងរស្មី ភេទប្រុស អាយុ ១៧ឆ្នាំ មុខរបរកម្មករសំណង់ ទីលំនៅសព្វថ្ងៃ ភូមិមានជ័យ [redacted] ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី២២-០៣-២០០៦។

**ត្រូវជាប់ចោទពីបទៈ** ប្លន់ ( ទូរស័ព្ទដៃ និងនាឡិកា) ប្រព្រឹត្តនៅភូមិមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

**- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]គីមអាង** ភេទប្រុស អាយុ ១៥ឆ្នាំ ទីលំនៅសព្វថ្ងៃផ្ទះលេខ៥១០ ក្រុម១២ ក្រុងភ្នំពេញ។

- តាមបណ្តឹងឧទ្ធរណ៍លេខ ៥៤៥ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោ[redacted] **សីហា ហៅ ភ័ក្រ្ត** ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៩២ (ខ) ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

**ដំណើររឿងមានដូចតទៅ:**

តាមពាក្យបណ្តឹងចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] **គីមអាង** ថា កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ វេលាម៉ោង ២ជិតភ្លឺ ខ្លួនជិះមកដល់ចំណុចស្ពានស្ទឹងមានជ័យ ស្រាប់តែមានក្រុមក្មេងស្ទាវ ១ក្រុម ចោមរោមខ្លួន ម្នាក់យកកាំបិតតាំងតោមកភ្ជង់កខ្លួន រួចវាដោះយកនាឡិកា ១គ្រឿង ម៉ាកហ្គោលស្តា និងទូរស័ព្ទដៃ ១គ្រឿង ម៉ាកណូគា។ ពេលពួកវាធ្វើសកម្មភាព ខ្លួនឃើញមានម្នាក់ដេកមិនក្រោកធ្វើសកម្មភាពទេ ពួកវាហៅថា[redacted]**សីហា** ឱ្យមកជួយគេ វាដេកមិនក្រោកទៀត។ ដូចនេ[redacted]**សីហា** ពិតជាពុំបានចូលរួមធ្វើសកម្មភាពប្លន់ខ្លួនទេ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៩២ (ខ) ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោសឈ្មោះ [redacted] **សារ៉ាក់** ភេទប្រុស អាយុ ២១ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ៦ឆ្នាំ ( ប្រាំមួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦. ឈ្មោះ[redacted]សុងវស្នី ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ[redacted] សីហា ភេទប្រុស អាយុ ១៦ឆ្នាំ ដាក់ពន្ធនាគារម្នាក់ៗកំណត់រយៈពេល ៥ឆ្នាំ ( ប្រាំឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ តទៅ និងឈ្មោ[redacted] **ស៊ីថា ហៅ ថា** ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ៧ឆ្នាំ ( ប្រាំពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន។

- ពីបទ : ប្លន់ ( ទូរស័ព្ទដៃ និងនាឡិកា)

- ប្រព្រឹត្តនៅភូមិមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦

- បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២- វត្ថុតាងមានៈ កាំបិទតាំងតោដងស មុខស ចំនួន០១ សម្រេចរឹបអូសបំផ្លាញចោល និងនាឡិកាម៉ាកហ្គោស្តារ ( Gold Star) ពណ៌ក្រហមមួយគ្រឿងសម្រេចប្រគល់ជូនម្ចាស់ដើមវិញ។

៣- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោ[redacted]សារ៉ាក់. ឈ្មោះ [redacted] សុងវស្នី. ឈ្មោ[redacted] សីហា និងកំបាំងមុខជនជាប់ចោទឈ្មោ[redacted]ស៊ីថា និងជនរងគ្រោះ សម្រេចមិនផ្លូវរឿងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្តឹងឧទ្ធរណលេខ ៥៤៩ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] សីហា ហៅ ភ័ក្ត្រ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៩២ (ខ) ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០០៨ របស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ចៅក្រមអានសង្ខេបរបាយការណ៍រឿង

ជនជាប់ចោទឈ្មោះ [redacted] សីហា ហៅ ភ័ក្ត្រ ឆ្លើយថា : ខ្លួនមានអាយុ ១៩ឆ្នាំ ពេលគេចោទខ្លួនៗមានអាយុ ១៦ឆ្នាំ។ ពេលកើតហេតុខ្លួននៅស្ទឹងមានជ័យ ។ ខ្លួនអត់បានធ្វើអំពើល្មើសច្បាប់ទេ ខ្លួនឮគេស្រែកហៅ ទើបទៅ ។

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] សីហា ឆ្លើយនៅតុលាការតុលាការក្រុងភ្នំពេញ ។

ជនជាប់ចោទឈ្មោះ [redacted] សីហា ហៅ ភ័ក្ត្រ ឆ្លើយថា : រាល់ចម្លើយទាំងអស់នេះខ្លួនមិនបានឆ្លើយទេ គឺប៉ូលីសវាយបង្ខំខ្លួនដល់សន្លប់ ។ ខ្លួនចាំគេលើកខោអាវនៅម្តុំប្តូរស្តាយ ស្ទឹងមានជ័យ មានឈ្មោះ ហ៊ិន, ឡៃម, ប៉ែន, រតនា។ ពេលក្រុមក្មេងស្ទាវយកកាំបិតទៅភ្ជង់ជនរងគ្រោះ ខ្លួនដើរចូលវត្ត ឮសូរគេស្រែកឱ្យជួយ ប្រហែលជាជនរងគ្រោះ ។ ខ្លួនអត់បានទទួលរបស់របរដែលក្រុមនោះយកបានទេ ខ្លួនអត់ស្គាល់ពួកក្រុមស្ទាវទេ ។ ខ្លួនតែងតែដេករងចាំលើកឥវ៉ាន់ ផ្ទះខ្លួននៅឃុំដំណាក់ធំ ។ កន្លែងដែលត្រូវលើកឥវ៉ាន់ គឺមេការឱ្យខ្លួនមកចាំ។ ខ្លួនលើកឥវ៉ាន់ជាងមួយខែហើយ ហើយខ្លួនស្គាល់អ្នកដែលលើកឥវ៉ាន់ជាមួយគ្នាមានឈ្មោះ សីហា ដូចខ្លួនដែរ ។ ចម្លើយនៅសវនាការតុលាការក្រុងភ្នំពេញ គ្មាននរណាវាយខ្លួនទេ។ គេចាប់ខ្លួននៅថ្ងៃទី ២២ ខែមីនា ឆ្នាំ២០០៦ វេលាម៉ោង ២ ជនរងគ្រោះឈ្មោះ [redacted] គីមអាង ។ ខ្លួនមិនដឹងអ្នកណាយកនាឡិកាទៅលក់ទេ ។ គេធ្លាប់បបួលខ្លួនទៅប្លន់ដែរ តែខ្លួនមិនបានប្រព្រឹត្តទេ ។ ខ្លួនដឹងថា ពេលកើតហេតុឮសូរគេស្រែកឱ្យជួយ តែខ្លួនមិនបានទៅជួយទេ ។ ខ្លួនស្គាល់អ្នកធ្វើដំណើរជាមួយខ្លួនម្នាក់ឈ្មោះ សីហា ឥវ៉ាន់ដែលត្រូវលើកដាក់ គឺមានចំងាយប្រហែល ៣ km ពីវត្តស្ទឹងមានជ័យ ។ ខ្លួនលើកឥវ៉ាន់ ២០ដង រឺ ៣០ដង ទើបបើកលុយ ពេលកើតហេតុខ្លួនឮគេស្រែក តែមិនបានទៅជួយ គ្រាន់តែដឹងថាមានឈ្មោះ សីហា ម្នាក់ដែរ ពួកខ្លួនទាំងពីរបានលើកឥវ៉ាន់ជាមួយគ្នា ហើយទៅផឹកទឹកក្រឡុក ពេលប៉ូលីសចាប់ខ្លួនៗនៅផ្ទះអ្នកជិតខាង ពេលដល់បុស្តិ៍គេវាយខ្លួនដល់សន្លប់ ។ អ្នកផ្សេងទៀតខ្លួនមិនដឹងគេចាប់ដាក់នៅឯណាទេ ។ សំណូមពរ សុំរួចផុតពីការចោទប្រកាន់ ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

រឿងនេះអយ្យការសូមតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩២ (ខ) ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការ លើកលែងតែចំណុចទី១ ដែលបានផ្តន្ទាទោសលើជនជាប់ចោទ [redacted] សីហា ហៅ ភ័ក្ត្រ នោះគួរបដិសេធចោល ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

លោក [redacted] សុភី មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] សីហា ធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនមានមុខរបរជាអ្នកលើកឥវ៉ាន់ ដាក់កុងទីន័ររបស់ក្រុមហ៊ុន ប្តូរស្តាយ នៅថ្ងៃទី ២១ មេការកូនក្តីខ្លួនបានឱ្យកូនក្តីខ្លួនមករងចាំនៅមុខ ៥/

វត្តស្ទឹងមានជ័យ ហើយក្រោយមកអ្នកមកចាំបាននាំគ្នាទៅផឹកទឹកក្រឡុក ហើយនៅតែកូនក្តីខ្លួន និងគ្នាម្នាក់ទៀត លុះពេលកើតហេតុនៅថ្ងៃទី ២២ កូនក្តីខ្លួនបានឃើញគេធ្វើសកម្មភាព តែមិនបានចូលរួមទេ សូមប្រធានក្រុមប្រឹក្សាមេត្តាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីការចោទប្រកាន់ និងដោះលែងកូនក្តីខ្លួន។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] សីហា
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

<u>សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:</u>

១- បណ្តឹងឧទ្ធរណលេខ៩៤៩ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] សីហា ហៅ ភ័ក្រ្ត ធ្វើឡើងនៅក្នុងកំណត់ច្បាប់ ។

២- លិខិតលេខ ០៩៧ កអក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩ របស់អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាសុំឱ្យទទួលស្គាល់លោក [redacted] សុភី ជាមេធាវីការពារជនជាប់ចោទ [redacted] សីហា មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣- តាមចម្លើយជនជាប់ចោទថា កាលពីយប់អាធ្រាត្រកើតហេតុថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ បក្សពួកខ្លួនមានឈ្មោះ [redacted] សុងរស្មី, [redacted] សារ៉ាត់, [redacted] ស៊ីថា និង [redacted] សីហា ពិតជាបានចាប់គម្រាមជនរងគ្រោះដោយយកកាំបិតតាំងតោភ្ជង់ជនរងគ្រោះ ដោយយកនាឡិកាដៃ និងយកទូរស័ព្ទមែន។ តែខ្លួនមិនបានចូលរួមទេ គ្រាន់តែដើរតាមទេ។

៤- ជនជាប់ចោទពិតជាសហចារីក្នុងអំពើប្លន់ ប្រព្រឹត្តនៅភូមិមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យក្រុងភ្នំពេញ កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦។

៥- មានពិរុទ្ធភាពលើជនជាប់ចោទ ពីបទ ប្លន់ ប្រព្រឹត្តនៅភូមិមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យក្រុងភ្នំពេញ កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៦- សាលក្រមព្រហ្មទណ្ឌលេខ ៩២ (ខ) ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៦ របស់សាលាដំបូងក្រុងភ្នំពេញសម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ លើកលែងតែកម្រិតទណ្ឌកម្ម គួរកែប្រែឱ្យបានត្រឹមត្រូវតាមភាពជាអនីតិភាពរបស់ជនជាប់ចោទ តាមសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ។

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្តី</u>

១- ទទួលបណ្តឹងឧទ្ធរណលេខ៩៤៩ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] សីហា ហៅ ភ័ក្រ្ត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២- ទទួលស្គាល់លោក [redacted] សុភី ជាមេធាវីការពារជនជាប់ចោទត្រឹមត្រូវតាមច្បាប់ ។

៣- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩២ (ខ) ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៦ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការ លើកលែងតែកម្រិតទណ្ឌកម្មលើជនជាប់ចោទ [redacted] សីហា ហៅ ភ័ក្ត្រ ត្រូវកែជា ៣ឆ្នាំវិញ ក្រៅពីនេះទុកនៅដដែល ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារជនជាប់ចោទ ។

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និង ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រុមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី18 ខែ 02 ឆ្នាំ២០១៤
ក្រឡាបញ្ជី
[redacted]

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]